ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ០១២៤.៩៥ ៣២៥

# សេចក្តីណែនាំ
## ស្តីពី
## ការពង្រឹងប្រសិទ្ធភាពការងាររបស់រដ្ឋបាលឃុំ សង្កាត់ ក្នុងរយៈពេលយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦

- យោងព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- យោងអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរមុខងារ អំណាច តួនាទី ភារកិច្ច ទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់
- យោងបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦

ដើម្បីអនុវត្តឲ្យបានត្រឹមត្រូវតាមវិធានដែលមានចែងក្នុងច្បាប់ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ព្រមទាំងដើម្បីពង្រឹងប្រសិទ្ធភាពការងាររបស់រដ្ឋបាលឃុំ សង្កាត់ ក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋប្រកបដោយភាពរលូន ក្នុងរយៈពេលយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំដូចខាងក្រោម៖

### ១-ចំពោះមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

ចាប់ពីពេលបើកយុទ្ធនាការឃោសនាបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោត មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវខិតខំពង្រឹងសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការជាមួយគ្នាដើម្បីបំពេញការងារឲ្យបានត្រឹមត្រូវស្របតាមគោលការណ៍ច្បាប់ និងត្រូវប្រកាន់ជំហរអព្យាក្រឹត និងមិនលំអៀង។

ចំពោះមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានបំណងចូលរួមធ្វើសកម្មភាពយុទ្ធនាការឃោសនាបោះឆ្នោត មិនត្រូវប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឥទ្ធិពលនៃរដ្ឋបាលឃុំ សង្កាត់ និងមិនត្រូវប្រើប្រាស់មធ្យោបាយសម្ភារ ថវិការបស់រដ្ឋបាលឃុំ សង្កាត់

ទៅបម្រើឲ្យសកម្មភាពរបស់គណបក្សនយោបាយណាមួយ ឬបម្រើឲ្យសកម្មភាពយុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយឡើយ។

ក្នុងអំឡុងពេលនៃយុទ្ធនាការឃោសនាបោះឆ្នោត ដើម្បីពង្រឹងប្រសិទ្ធភាពការងារក្នុងឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ត្រូវពិភាក្សាគ្នារៀបចំបែងចែកវេនប្រចាំការតាមថ្ងៃនីមួយៗនៅសាលាឃុំ សង្កាត់ ដោយស្មើភាព ក្នុងចំណោមមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង រួមទាំងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដទៃទៀត ដើម្បីធានាឲ្យមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងតិចចំនួន០១(មួយ)រូប សម្រាប់ប្រចាំការតាមថ្ងៃនីមួយៗ។ លិខិតចាត់តាំងវេនប្រចាំការនេះ ត្រូវថតចម្លងចំនួន ០១(មួយ)ច្បាប់ ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ០១(មួយ)ច្បាប់ជូនគណៈអភិបាលក្រុង ស្រុក ខណ្ឌសាមី និង ០១(មួយ)ច្បាប់ទៀតបិទផ្សាយនៅតាមសាលាឃុំ សង្កាត់។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលត្រូវបានចាត់តាំងឲ្យប្រចាំការនេះ ត្រូវទទួលសម្របសម្រួលកិច្ចការរដ្ឋបាលប្រចាំថ្ងៃ ការអភិវឌ្ឍ សំណើ ឬសំណូមពរផ្សេងៗរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន ស្របតាមគោលការណ៍ច្បាប់ និងលិខិតបទដ្ឋាននានាសម្រាប់គ្រប់គ្រងឃុំ សង្កាត់។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលត្រូវបានចាត់តាំងឲ្យប្រចាំការ មិនត្រូវចូលរួមក្នុងយុទ្ធនាការឃោសនារបស់គណបក្សនយោបាយណាមួយនៅក្នុងថ្ងៃដែលសាមីខ្លួនត្រូវប្រចាំការនោះឡើយ។ ក្នុងពេលប្រចាំការ ករណីមានកិច្ចការដែលត្រូវសម្រេច និងចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលទទួលវេនប្រចាំការនោះ ត្រូវទាក់ទងជាបន្ទាន់ជាមួយមេឃុំ ចៅសង្កាត់ ដើម្បីដោះស្រាយការងារទាំងនោះឲ្យសមស្របទៅតាមគោលការណ៍ច្បាប់។

**២-ចំពោះស្មៀនឃុំ សង្កាត់**

ស្មៀនឃុំ សង្កាត់ ដែលជាមន្ត្រីរាជការស៊ីវិលត្រូវមានវត្តមានជាប្រចាំនៅសាលាឃុំ សង្កាត់ នៅរៀងរាល់ថ្ងៃការងារ។ ស្មៀនឃុំ សង្កាត់ត្រូវប្រកាន់អាកប្បកិរិយាការងារស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ដូចមន្ត្រីរាជការស៊ីវិលដទៃទៀតដែរ។

**៣-ចំពោះមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ**

មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិត្រូវអនុវត្តឲ្យបានម៉ឺងម៉ាត់តាមសេចក្តីណែនាំរួមលេខ ០១១ សណន ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨ រវាងក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសៀវភៅណែនាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីភារកិច្ច និងកាតព្វកិច្ចរបស់មេភូមិ អនុប្រធានភូមិ ក្នុងដំណើរការបោះឆ្នោត។

មេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិ ដែលមានបំណងចូលរួមក្នុងយុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ត្រូវដាក់ពាក្យសុំច្បាប់ឈប់សម្រាកពីការងារ ទៅមេឃុំ ចៅសង្កាត់សាមី ដើម្បីចូលរួមក្នុងសកម្មភាពយុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ (តាមគំរូពាក្យសុំច្បាប់ភ្ជាប់មកជាមួយ)។ ប៉ុន្តែ ក្នុងភូមិនីមួយៗ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ មិនត្រូវដាក់ពាក្យសុំឈប់សម្រាកក្នុងពេលតែមួយជាមួយគ្នា ដោយមិនមានអ្នកប្រចាំការដោះស្រាយការងារសាធារណៈក្នុងភូមិនោះឡើយ។ ពាក្យសុំច្បាប់ឈប់សម្រាកនេះ ត្រូវថតចម្លងចំនួន០១(មួយ)ច្បាប់ ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត។

ក្នុងអំឡុងពេលនៃការឈប់សម្រាកពីការងារដើម្បីចូលរួមក្នុងសកម្មភាពឃោសនាការឃោសនាបោះឆ្នោត មេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិ មិនមែនជាមន្ត្រីដឹកនាំភូមិឡើយ។

អ្នកដឹកនាំភូមិដទៃទៀតដែលមិនបានសុំច្បាប់ឈប់សម្រាកពីការងារ គឺជាអ្នកដឹកនាំភូមិតាមឋានានុក្រមដែលត្រូវបម្រើកិច្ចការសាធារណៈក្នុងភូមិប្រកបដោយតម្លាភាព និងត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលំអៀង ក្នុងការបោះឆ្នោត ហើយមន្ត្រីភូមិទាំងនោះមិនត្រូវចូលរួមក្នុងសកម្មភាពឃុទ្ធនាការឃោសនាបោះឆ្នោត របស់គណបក្សនយោបាយណាមួយឡើយ ប្រសិនបើសាមីខ្លួនមិនមានច្បាប់ឈប់សម្រាកពីការងារ។

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រុមប្រឹក្សារាជធានី ខេត្ត គណៈអភិបាលរាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់ចែងផ្សព្វផ្សាយឲ្យបានទូលំទូលាយ និងណែនាំអនុវត្តសេចក្ដីណែនាំនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ - កាលប្បវត្តិ